# កិច្ចប្រជុំស្តីពី
# ការពិនិត្យស្ថានភាពនៃការអនុវត្តការងារនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧

---

# បទបង្ហាញស្តីពី
# ទំនាក់ទំនងអន្តររដ្ឋបាល និងការគាំទ្រ


**បង្ហាញដោយ៖ លោក ឈិន ទេពិរម្យ**
ទីប្រឹក្សាគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប

# មាតិកា

១.ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានសំខាន់ៗ
២. ទំនាក់ទំនងអន្តររដ្ឋបាលក្រុង ស្រុក ខណ្ឌ
៣. គោលការណ៍
៤. បញ្ហាប្រឈម

# ១. ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានសំខាន់ៗ



# ២. ទំនាក់ទំនងអន្តររដ្ឋបាលក្រុង ស្រុក ខណ្ឌ



# ការបង្កើតទំនាក់ទំនងអន្តររដ្ឋបាល គឺ

**ដើម្បី ៖**

- លើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវានានា
- បង្កើនលទ្ធភាពក្នុងការកៀរគរធនធាន
- សម្រេចបាននូវប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធាន
- លើកកម្ពស់ខ្សែគណនេយ្យភាព
- សម្របសម្រួលវិវាទនានានៅមូលដ្ឋាន និង
- ជៀសវាង និងសម្របសម្រួលភាពមិនចុះសម្រុងរវាងក្រុមប្រឹក្សា ស្រុកជាមួយមន្ទីរ និងអង្គភាពពាក់ព័ន្ធ។

# ៣. គោលការណ៍

**គោលការណ៍នៃទំនាក់ទំនងអន្តររដ្ឋបាល គឺ៖**

- **ការប្រាស្រ័យទាក់ទងគ្នា** ៖ ត្រូវផ្តល់ និងចែករំលែកព័ត៌មាននានា ពិគ្រោះយោបល់ និងរៀនសូត្រពីគ្នាទៅវិញទៅមក។

- **ការគោរពស្វ័យភាពទៅវិញទៅមក** ៖ ត្រូវគោរពស្វ័យភាពរបស់ក្រុមប្រឹក្សានីមួយៗក្នុងការធ្វើសេចក្តីសម្រេច

- **ការសម្របសម្រួល** ៖ ត្រូវមានការសម្របសម្រួលរវាងអ្នកពាក់ព័ន្ធនានា ដើម្បីធានាឱ្យក្រុមប្រឹក្សា និងស្ថាប័នពាក់ព័ន្ធអាចធ្វើការងាររួមគ្នាកាន់តែរលូន មានប្រសិទ្ធភាពខ្ពស់ និងជៀសវាងការធ្វើការងារត្រួតគ្នា ។

- **កិច្ចសហប្រតិបត្តិការ** ៖ ចូលរួមអនុវត្តការងារជាមួយគ្នា ឬគាំទ្រគ្នាទៅវិញទៅមក ក្នុងការបំពេញការងារដើម្បីសម្រេចគោលដៅរួម។

# ទំនាក់ទំនងរវាងរដ្ឋបាលក្រុង ស្រុកជាមួយរដ្ឋបាលខេត្ត

**រដ្ឋបាលខេត្ត**

## រដ្ឋបាលក្រុង ស្រុក ៖

- ស្នើសុំការគាំទ្របច្ចេកទេស និងការអភិវឌ្ឍសមត្ថភាព
- ផ្តល់ព័ត៌មានអំពីបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋ
- ចូលរួមប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមក្នុងគណៈកម្មាធិការនានា
- ចូលរួមក្នុងការរៀបចំផែនការអភិ. និងកម្មវិធីវិនិយោគខេត្ត
- ការអនុវត្តមុខងារ

## រដ្ឋបាលខេត្ត ៖

- សម្របសម្រួលការគាំទ្របច្ចេកទេស និងអភិវឌ្ឍន៍សមត្ថភាព
- សម្របសម្រួលភាពមិនចុះសម្រុងគ្នា
- ចាត់វិធានការឆ្លើយតបបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋ
- គាំទ្រការអនុវត្តមុខងារ
- ពិនិត្យនីត្យានុកូលភាព
- ណែនាំ និងតម្រង់ទិស

**រដ្ឋបាលក្រុង ស្រុក**

# ទំនាក់ទំនងរវាងរដ្ឋបាលក្រុង ស្រុកជាមួយរដ្ឋបាលឃុំ សង្កាត់

**រដ្ឋបាលក្រុង ស្រុក**

*រដ្ឋបាលក្រុង ស្រុក ៖*

- ចូលរួមកិច្ចប្រជុំឃុំ សង្កាត់
- ការរៀបចំ និងអនុវត្តផែនការអភិ. និងកម្មវិធីវិនិយោគឃុំ សង្កាត់
- ការអនុវត្តមុខងារជាការតព្វកិច្ច និងមុខងារជាជម្រើសរបស់ឃុំ សង្កាត់
- ត្រួតពិនិត្យ វាយតម្លៃ និងគាំទ្រការអភិវឌ្ឍសមត្ថភាពឃុំ សង្កាត់
- ផ្តល់យោបល់លើការពិនិត្យនីត្យានុកូលភាពកិច្ចការឃុំ សង្កាត់

*ឃុំ សង្កាត់ ៖*

- ចូលរួមកិច្ចប្រជុំក្រុង ស្រុក
- ការរៀបចំ និងអនុវត្តផែនការអភិ. និងកម្មវិធីវិនិយោគក្រុង ស្រុក
- ការចូលរួមក្នុងគណៈកម្មាធិការនានា
- ការរៀបចំវេទិការ
- ការសម្របសម្រួលភាពមិនចុះសម្រុង
- ការស្នើការគាំទ្របច្ចេកទេស និងការអភិវឌ្ឍសមត្ថភាព

**រដ្ឋបាលឃុំ សង្កាត់**

# ទំនាក់ទំនងរវាងរដ្ឋបាលក្រុង ស្រុកជាមួយការិយាល័យជំនាញ

**រដ្ឋបាលក្រុង ស្រុក**

## រដ្ឋបាលក្រុង ស្រុក ៖

- ជូនដំណឹងដល់ការិ.អំពី ផែនការ និង ថវិកា ដែលមិនឆ្លើយតបតម្រូវការ
- អញ្ជើញតំណាងការិ. ចូលរួមប្រជុំ
- ណែនាំ និងដោះស្រាយបញ្ហានានា
- ចែករំលែកព័ត៌មាន
- ការពិគ្រោះយោបល់
- ដាក់បញ្ចូលតំណាងការិ. ក្នុង គ.ស.ប និង គ.ក.ស.ក ឬក្រុមការងារនានា
- ការតែងតាំង

## ការិយាល័យជំនាញ ៖

- ផ្តល់ការគាំទ្របច្ចេកទេស
- ចូលរួមប្រជុំរបស់ក្រុមប្រឹក្សាស្រុក
- ការអនុវត្តសេចក្តីសម្រេច និងដីកា
- ចូលរួមក្នុងសមាសភាពគណៈកម្មា.
- ការឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ
- ការដាក់បញ្ចូលផែនការ និងថវិការបស់ការិទៅក្នុង DP & IP
- រាយការណ៍អំពីការអនុវត្ត

**ការិយាល័យជំនាញ**

# ទំនាក់ទំនងរវាងរដ្ឋបាលក្រុង ស្រុកជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ

**ក្រសួងមហាផ្ទៃ**

## រដ្ឋបាលក្រុង ស្រុក៖

- ស្នើសុំការគាំទ្រ ការណែនាំ និងតម្រង់ទិស
- សំណើបង្កើត រំសាយ ឬ កែសម្រួលការិ.
- ស្នើសុំជ្រើសរើស ផ្លាស់ប្តូរ ឬដកហូត នាយករដ្ឋបាល អភិបាល អភិបាលរង
- សុំយោបល់លើសេចក្តីព្រាងដីកា ឬ សេចក្តីសម្រេចមិនច្បាស់លាស់
- ស្នើសុំការសម្របសម្រួលភាពមិនចុះសម្រុងគ្នា

## ក្រសួងមហាផ្ទៃ ៖

- ផ្តល់ការណែនាំ ការគាំទ្រ និងការតម្រង់ទិស
- ទទួលខុសត្រូវក្នុងការដោះស្រាយរាល់ទង្វើមិនស្របច្បាប់ ឬ សេចក្តីសម្រេចមិនស្របច្បាប់
- សម្របសម្រួលភាពមិនចុះសម្រុងគ្នារវាងស្រុក និង ឃុំ
- ឆ្លើយតបនឹងការស្នើសុំនានា ពីរដ្ឋបាលក្រុង ស្រុក

**រដ្ឋបាលក្រុង ស្រុក**

# ទំនាក់ទំនងរវាងរដ្ឋបាលក្រុង ស្រុកជាមួយ ក្រសួង ស្ថាប័ន

**គ.ជ.អ.ប**

**រដ្ឋបាលក្រុង ស្រុក ៖**

- ស្នើសុំការគាំទ្រផ្នែកគោលនយោបាយ
- ចូលរួមពិគ្រោះយោបល់ពាក់ព័ន្ធនឹងការផ្ទេរមុខងារ និងធនធាន
- ដាក់បញ្ចូលមុខងារដែលបានទទួលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ
- អនុវត្តមុខងារដែលបានផ្ទេរ
- ស្នើសុំការសម្របសម្រួលភាពមិនចុះសម្រុងគ្នាជាមួយក្រសួង ស្ថាប័ន

**ក្រសួងមហាផ្ទៃ ៖**

- ផ្តល់ការណែនាំ ការគាំទ្រ និងការតម្រង់ទិសអំពីកំណែទម្រង់
- សម្របសម្រួលការផ្ទេរមុខងារ ទៅឲ្យរដ្ឋបាលក្រុង ស្រុក
- តាមដាន និងគាំទ្រការអនុវត្ត មុខងារដែលបានផ្ទេរ
- សម្របសម្រួលភាពមិនចុះសម្រុងគ្នាជាមួយក្រសួង ស្ថាប័ន

**រដ្ឋបាលក្រុង ស្រុក**

# ទំនាក់ទំនងរវាងរដ្ឋបាលក្រុង ស្រុកជាមួយ រដ្ឋបាលក្រុង ស្រុក

**រដ្ឋបាលក្រុង ស្រុក** ⟺ **រដ្ឋបាលក្រុង ស្រុក**

បញ្ហាសំខាន់ៗដែលតម្រូវឱ្យមានការទំនាក់ទំនងរវាងក្រុមប្រឹក្សាពីរ ឬ ច្រើនរួមគ្នា ៖

- បញ្ហាទាំងឡាយដែលមានផលប៉ះពាល់ឆ្លងព្រំប្រទល់ពីស្រុកមួយ ទៅស្រុកមួយទៀត ពីស្រុកមួយទៅក្រុងមួយ ឬ ពីស្រុកមួយ ទៅ ខណ្ឌមួយ ដូចជា បញ្ហាគ្រឿងញៀន បញ្ហាអសន្តិសុខ បញ្ហា ចោរកម្ម បញ្ហាចរាចរណ៍ បញ្ហាជំងឺឆ្លងរបស់មនុស្ស សត្វ និងបញ្ហាបរិស្ថាន ( ទីតាំងចាក់កាកសំណល់រឹងរាវ... )
- សកម្មភាពនានាដែលលើកកម្ពស់ជីវភាពរស់នៅ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដូចជា ការរៀបចំតំបន់ទេសចរណ៍ធម្មជាតិ ការរៀបចំសហគមន៍ព្រៃឈើ ការគ្រប់គ្រង និងបែងចែកទឹកស្រោចស្រព ការសម្របសម្រួលក្នុងការផ្តល់សេវា។ល។
- សកម្មភាពនានាពាក់ព័ន្ធនឹងការចែករំលែកចំណេះដឹង មេរៀន បទពិសោធន៍ និងធនធាននានា។

## ៤. បញ្ហាប្រឈម

- ការទំនាក់ទំនងរវាងរដ្ឋបាលមួយ ទៅរដ្ឋបាលមួយទៀត នៅតែអនុវត្តតាមបែបឋានានុក្រមពីលើពីខេត្ត ទៅក្រុង ស្រុក ទៅឃុំ សង្កាត់
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ ពុំមានមន្ត្រីគ្រប់គ្រាន់ក្នុងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព ឃុំ សង្កាត់
- រដ្ឋបាលក្រុង ស្រុក ពុំមានថវិកាក្នុងការគាំទ្រដល់តម្រូវការរបស់រដ្ឋបាលឃុំ សង្កាត់
- រដ្ឋបាលក្រុង ស្រុក ទទួលបានការគាំទ្រតិចតួច (ទាំងធនធាន និងបច្ចេកទេស) ពីមន្ទីរ ការិយាល័យជំនាញ ។




# អរគុណ !